# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០២៥៤/១៩ ក.ប/ស.ជ.ណ.ប.ប

ថ្ងៃសុក្រ ៣ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពីការដាក់ពាក្យស្នើសុំមូលនិធិជាតិបណ្តុះបណ្តាល ដើម្បីកាត់បន្ថយភាពក្រីក្រ ជំហានទី២ ឆ្នាំ២០១៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់អង្គភាពបណ្តុះបណ្តាល ទាំងផ្នែកសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជិកានៅក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តឲ្យបានជ្រាបថា ជារៀងរាល់ឆ្នាំក្រសួងបានអនុវត្តថវិកាកម្មវិធីពេញលេញ ដែលក្នុងនោះមានកម្មវិធីមួយឈ្មោះថា "កម្មវិធីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩"។ ការអនុវត្តកម្មវិធីនេះក្រសួង នឹងផ្តល់ថវិកាមួយចំនួនតាមរយៈមូលនិធិជាតិបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រ សម្រាប់ផ្តល់ជូនដល់អង្គភាពបណ្តុះបណ្តាលដែលស្របច្បាប់ មានបទពិសោធន៍ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងឆ្លើយតបទៅតាមលក្ខណៈវិនិច្ឆ័យដែលក្រសួងបានកំណត់។ ចំពោះជំនាញបណ្តុះបណ្តាលមាន០២ប្រភេទគឺ ទី០១ ផ្នែកបច្ចេកទេស ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម(០៤ខែ) និងទី០២ កសិកម្ម(០១សប្តាហ៍) ដែលផ្តោតលើវិស័យអាទិភាពទាំង០៥រួមមាន សំណង់(Construction) មេកានិករថយន្ត (Auto Mechanic) កុំព្យូទ័រ/ធុរកិច្ច(ICT/Business) អគ្គិសនី(Electrical Works) កម្មន្តសាល(Manufacturing) ដោយក្រុមគោលដៅដែលត្រូវធ្វើការបណ្តុះបណ្តាល រួមមាន ជនទីទ័លក្រ ស្ត្រីមេម៉ាយ ក្មេងកំព្រា សិស្សបោះបង់ការសិក្សា ជនពិការ និងជនបាត់បង់ឱកាសការងារ ។ល។

អាស្រ័យហេតុនេះ សូមអង្គភាពបណ្តុះបណ្តាលដែលមានលក្ខណៈសម្បត្តិសមស្រប និងឆ្លើយតបទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ខាងលើ អញ្ជើញមកទាក់ទងនិងដាក់ពាក្យស្នើសុំមូលនិធិជាតិបណ្តុះបណ្តាលនៅការិយាល័យបណ្តុះបណ្តាលក្រៅប្រព័ន្ធ នៃនាយកដ្ឋានបណ្តុះបណ្តាល ដែលមានអាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃសុក្រ ១ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកចាប់ពីម៉ោង ៧:៣០នាទី ដល់ ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០នាទី។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
- គ្រឹះស្ថានសិក្សាក្រោមឱវាទ

"ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ
- ទូរស័ព្ទទំនាក់ទំនង: ០១២ ៦២២ ៧៦៧ /០៩៥ ៩៥៨ ៨៦៦